ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៩ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន:

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

១៣_៣_១៩៩៥ - ព្រះរាជក្រមលេខ នស/រកត ០៣៩៥/០១ .... ៣៧៣

២. ព្រះរាជក្រឹត្យ

១៥_៣_១៩៩៥ - ព្រះរាជក្រឹត្យលេខ នស/រកត ០៣៩៥/២៨ .... ៣៧៤

១៥_៣_១៩៩៥ - ព្រះរាជក្រមលេខ នស/រកត ០៣៩៥/២៩ .... ៣៧៥

១៥_៣_១៩៩៥ - ព្រះរាជក្រមលេខ នស/រកត ០៣៩៥/៣០ .... ៣៧៦

II- ទីស្តីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

១១_៣_១៩៩៥ - អនុក្រឹត្យលេខ ៣៤ អនក្រ ស្តីពីការបង្កើតអង្គភាពសំរាប់សំរបសំរួលបញ្ហាកងទ័ព
វិសាយ និង សមាហរ័ណកម្មចូលក្នុងសង្គមជាតិនូវអតីតទាហានខ្មែរក្រហម ៣៧៧

៩_៣_១៩៩៥ - អនុក្រឹត្យលេខ ៣១ អនក្រ ស្តីពីការចូលនិវត្តន៍មន្ត្រីរាជការ ៣៧៩

៩_៣_១៩៩៥ - អនុក្រឹត្យលេខ ៣២ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៨០

១០_៣_១៩៩៥ - អនុក្រឹត្យលេខ ៣៣ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៨១

១០_៣_១៩៩៥ - អនុក្រឹត្យលេខ ៣៤ អនក្រ ស្តីពីការមេដាយស្ថាបនាជាតិ ៣៨២

១១_៣_១៩៩៥ - អនុក្រឹត្យលេខ ៣៥ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៨៣

២. សេចក្តីសំរេច

១១_៣_១៩៩៥ - សេចក្តីសំរេចលេខ ២៤ សសរ ស្តីពីការផ្ទេរសិទ្ធិ ៣៨៤

៨. ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

១៣-៣-១៩៩៥ - ប្រកាសលេខ ១៩១ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះ " សាលាមត្តេយ្យមិត្តភាព ហាណូយ " ទៅជា " សាលាបឋមសិក្សាមិត្តភាពភ្នំពេញ- ហាណូយ " ៤០២

៩. ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

ប្រកាស

១៣-៣-១៩៩៥ - ប្រកាសលេខ ៥៨/៩៥ កធស ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រីរាជការ ៤០៣

គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងលោកជូន ឌេក ថារិទ្ធ និងលោក យិន សុចិនចិន្តា ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៣ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ

-តាមសំណើរបស់ អភិបាលខេត្ត កំពត

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ថ្នាក់លេខ ១ ជូនចំពោះលោក អ៊ុយ សឺខ ប្រធានសណ្ឋាគារឌីយ៉ាម៉ង់ ដែល បានកសាងអាគារសិក្សាមួយខ្នង នៅវត្តកោះរាំង ឃុំទូកមាស ខាងលិច ស្រុក បន្ទាយមាស ខេត្ត កំពត អស់ប្រាក់ ៦០ លាន រៀល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៤ អនក្រ
ស្តីពីការ ជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់អភិបាលខេត្ត កំពត

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះឯកឧត្តម **គៀង វ៉ាង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និង លោកជំទាវ ដែលបានចិត្តសប្បុរសបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមក្នុងការកសាងសមិទ្ធផលផ្សេងៗ ជាប្រយោជន៍សាធារណៈ ក្នុងខេត្តកំពតអស់ទឹកប្រាក់សរុប ១០៥.៥០០.០០០រៀល និង ៣០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៥ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណូមពររបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

សំរេច

មាត្រា ១ : តែងតាំងលោកវេជ្ជបណ្ឌិត **ថូ គីមប៉ោ** អតីតប្រធានស្នងការសុខាភិបាល យោធានៃក្រសួងការពារជាតិ ជាព្រឹទ្ធបុរស នៃមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ជំនួសលោកព្រឹទ្ធបុរសលោកវេជ្ជបណ្ឌិត **លី ប៉ូ** ដែលបានសុំចូលនិវត្តន៍ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ

នៃក្រសួង រដ្ឋលេខាធិការដ្ឋាន ដែលមានការពាក់ព័ន្ធ និង លោកដែលមាននាមក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

***

២. សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៤ សសរ
ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមការងារចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **អ៊ីង គៀត** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង ជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី ដើម្បីដោះស្រាយការងារប្រចាំថ្ងៃ របស់រាជរដ្ឋាភិបាល ក្នុងឱកាសដែលសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ ត្រូវយាង និងអញ្ជើញទៅបំពេញ

បេសកកម្មនៅឯបរទេសចាប់ពីថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៥ រហូតដល់ពេលសម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី ២ យាង និង អញ្ជើញត្រឡប់មកមាតុភូមិវិញ ។

ប្រការ ២ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តមឧបនាយករដ្ឋមន្ត្រីទាំងពីររូប ត្រូវទទួលបន្ទុកអនុវត្តការកិច្ចនេះ រៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា — ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៥

សេចក្តីសម្រេចលេខ ២៥ សសរ
ស្តីពី ការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណូមពរការងារចាំបាច់

សម្រេច

ប្រការ ១ ៖ ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ខាំ ចាន់គូ** រដ្ឋមន្ត្រីក្រសួងផែនការជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីទី ជំនួស ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃឯកឧត្តម គាត ឈន់ វិលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៦ សសរ
ស្តីពីការបង្កើតគណៈកម្មាធិការចំរុះសំរាប់
ពង្រីកសហប្រតិបត្តិការកម្ពុជា-វៀតណាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការមួយមានឈ្មោះថា : (គណៈកម្មាធិការសហប្រតិបត្តិការកម្ពុជា វៀតណាម) ដែលមានសមាសភាពដូចតទៅ :

១-	ឯកឧត្តម **អ៊ុង ហួត** រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	ប្រធាន
២-	ឯកឧត្តម **ម៉ែន យ៉េត** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី-វិមិត្រសិល្បៈ	សមាជិក
៣-	លោក **អ៊ុក សូម៉ារីម** ប្រធាននាយកដ្ឋានកិច្ចការនយោបាយក្រសួងមហាផ្ទៃ	សមាជិក
៤-	លោក **ថាច់ រ៉េន** ប្រធាននាយកដ្ឋាន នៃក្រសួងសាធារណការនិងដឹកជញ្ជូន	សមាជិក

៥_លោក **ប្រាក់ ឈៀង** ប្រធានមន្ទីរនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៦_លោក **ម៉ៅ ថូរ៉ា** ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសនៃក្រសួងពាណិជ្ជកម្ម សមាជិក

៧_លោក **ចិន្ត គាធី** ប្រធាននាយកដ្ឋាន ឧស្សាហកម្មទេសចរនៃក្រសួងទេសចរណ៍ សមាជិក

៨_លោក **ពេជ សោភ័ន្ត** ប្រធាននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំយុវជននិងកីឡា សមាជិក

៩_លោកស្រី **ឯម សាមឿន** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការសេដ្ឋកិច្ច នៃក្រសួងផែនការ សមាជិក

១០_លោក **ហ៊ុយ សេដ្ឋ** អនុប្រធានខុទ្ទកាល័យក្រសួងសុខាភិបាល សមាជិក

១១_លោក **គិត សេខ** អនុប្រធាននាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សមាជិក

១២_លោក **សយ សុខា** មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣_លោក **ភាន់ គុំ** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លេខាធិការ

១៤_លោក **អ៊ិក លីហេង** អនុប្រធាននាយកដ្ឋានអាស៊ីនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ លេខាធិការ

ប្រការ ២ : គណៈកម្មាធិការសហប្រតិបត្តិការកម្ពុជា-វៀតណាម មានភារកិច្ចដូចតទៅ:

- ជំនួយការអោយរាជរដ្ឋាភិបាលលើការងារ សហប្រតិបត្តិការ វិទ្យាសាស្ត្របច្ចេកវិទ្យា វប្បធម៌ និង សេដ្ឋកិច្ច ។
- រៀបចំគំរោងសហប្រតិបត្តិការ តាមវិស័យនីមួយៗ
- ជំរុញការអនុវត្តកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ
- ត្រួតពិនិត្យការអនុវត្តន៍កិច្ចសហប្រតិបត្តិការ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា
- សំរបសំរួលជាមួយបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការ កម្ពុជា-វៀតណាម ។
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលតាមកាលកំណត់

ប្រការ ៣ : គណៈកម្មាធិការសហប្រតិបត្តិការ កម្ពុជា_វៀតណាម មានសិទ្ធិអញ្ជើញឯកឧត្តមរបស់លោកមន្ត្រី អ្នកតំណាងស្ថាប័នដែលមានការពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការងារ សហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដើម្បីចូលរួមបំពេញ ការងារតាមការជាក់ស្តែង ។

ប្រការ ៤ : សមាជិកទាំងអស់នៃគណៈកម្មាធិការនេះ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

ប្រការ ៥ : គណៈកម្មាធិការសហប្រតិបត្តិការ កម្ពុជា_វៀតណាម មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាផ្លូវការ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងវប្បធម៌_វិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៧ សសរ
ស្តីពីការរៀបចំខ្សែរយៈ បែបបទ នៃការគ្រប់គ្រង និង បើកផ្តល់ថវិកា សំភារៈភស្តុភារ សំភារៈ បច្ចេកទេសផ្គត់ផ្គង់អោយកងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ

-យោងតាមស្មារតីប្រជុំអន្តរក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គសេនាធិការ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការធានាផ្គត់ផ្គង់ថវិកា ភស្តុភារ និង សំភារៈបច្ចេកទេស អោយកងយោធពលខេមរភូមិន្ទ

-ដើម្បីធានាគ្រប់គ្រង និង ផ្គត់ផ្គង់ថវិកា ភស្តុភារ សំភារៈបច្ចេកទេស ក្នុងកងយោធពលខេមរភូមិន្ទ អោយបានទាន់ពេលវេលា និង មានប្រសិទ្ធភាព ។

សំរេច

ប្រការ ១ : រៀបចំកែសំរួលខ្សែរយៈ និង បែបបទ នៃការគ្រប់គ្រង ការបើកផ្តល់ថវិកា សំភារៈភស្តុភារ សំភារៈបច្ចេកទេសផ្គត់ផ្គង់អោយកងយោធពលខេមរភូមិន្ទដូចមានចែងក្នុងប្រការខាងក្រោម ។

ប្រការ ២ : ក្រសួងហិរញ្ញវត្ថុ ផ្អែកតាមគំរោងថវិកាការពារជាតិដែលបានអនុម័តហើយ និងតាមផែនការចំណាយសាច់ប្រាក់របស់ក្រសួងការពារជាតិ និង អគ្គសេនាធិការ ត្រូវរៀបចំអោយរតនាគារតាម ខេត្ត-ក្រុង ទទួលបើកផ្តល់សាច់ប្រាក់ចំណាយអោយដល់កងឯកភាព នៃកងយោធពលខេមរភូមិន្ទ ដែលបោះទីតាំងនៅក្នុង ឬ នៅជិត ខេត្ត-ក្រុងនោះអោយបានគ្រប់គ្រាន់ និង ទាន់ពេលវេលាដោយបញ្ជូន សាច់ប្រាក់ទៅរតនាគារ នៃខេត្ត-ក្រុងនោះអោយបានទៀងទាត់តាមខែនីមួយៗនៃត្រីមាស ។

ប្រការ ៣ : ក្រសួងការពារជាតិ ក្រោយទទួលបានសច្ចាប័នលើថវិកាការពារជាតិប្រចាំឆ្នាំ ត្រូវធ្វើការបែងចែកមុខចំណាយណា ដែលក្រសួងត្រូវចំណាយផ្ទាល់ មុខចំណាយណាដែលត្រូវផ្តល់អោយអគ្គសេនាធិការចំណាយ ហើយប្រកាសថវិកាឆ្នាំអោយអគ្គសេនាធិការ រួមមានប្រាក់ចំណាយសំរាប់កិច្ចការរដ្ឋបាល ប្រាក់សំរាប់ហ្វឹកហ្វឺន សំរាប់ជួសជុលស្រាល ជួសជុលធ្ងន់ ការសាងសង់ជំរក ប្រាក់សំរាប់អន្តរាគមន៍សាធារណៈ ។

ប្រការ ៤ : ចំពោះប្រភេទមុខចំណាយជាប្រក្រតី រួមមានបៀវត្ស និងប្រាក់ចំណាត់ផ្សេងៗប្រាក់ ម្ហូបនិងប្រេង សំរាប់ការជួសជុលស្រាល និង ការថែរក្សាគ្រឿងយន្តសំភារៈបច្ចេកទេសជា ប្រចាំដែលបាន កំណត់ជាគោលការណ៍ហើយនោះ ក្រុមហិរញ្ញវត្ថុអគ្គសេនាធិការត្រូវធ្វើគំរោងសុំប្រាក់ប្រចាំ ត្រីមាស លំអិតតាមកងឯកភាព ផ្ញើមកនាយកដ្ឋានថវិកាក្រសួងការពារជាតិដោយមាន ការបញ្ជាក់ ឯកភាពពីនាយអគ្គសេនាធិការ ។ នាយកដ្ឋានថវិកាក្រសួងការពារជាតិក្រោយពីបានពិនិត្យឲ្យច្បាស់ លាស់ ត្រូវដាក់ក្នុងយោបល់ សហរដ្ឋមន្ត្រីការពារជាតិ រួចហើយបញ្ជូនទៅក្រសួងហិរញ្ញវត្ថុ និង ធនាគារជាតិ តាមរបៀបគិតពីខែម្តង ។

ប្រការ ៥ : ចំពោះប្រភេទមុខចំណាយចៃដន្យ និង ចាំបាច់ក្រៅពីថវិកាឆ្នាំ ដែលបានប្រកាសអគ្គសេនាធិការ ត្រូវធ្វើគំរោងឡើងមក ក្រសួងការពារជាតិ ដើម្បីស្នើសុំមករាជរដ្ឋាភិបាល សំរេចផ្តល់បន្ថែម ។

ប្រការ ៦ : ចំពោះការធានា សំភារៈភស្តុភារ បរិក្ខាផ្សេងៗក្រសួងការពារជាតិ ត្រូវធ្វើផែនការបើកផ្តល់អោយ អគ្គសេនាធិការ យោងទៅតាមប្រភេទបរិមាណពេលវេលា និង ទីកន្លែងដែលអគ្គសេនាធិការបាន គ្រោងឡើង ។ ផ្អែកតាមគំរោងនេះ ការិយាល័យជំនាញសេវាកិច្ចរបស់អគ្គសេនាធិការ ត្រូវធ្វើផែន ការកំណត់ការបែងចែកអោយកងឯកភាពនីមួយៗ ។ តាមគោលការណ៍ដោយមានការឯកភាព ពីនាយ អគ្គសេនាធិការ ។ ក្នុងករណីប្រើប្រាស់មិនគ្រប់គ្រាន់ត្រូវធ្វើគំរោងសុំបន្ថែម មកក្រសួងការពារ ជាតិ។

ប្រការ ៧ : ក្នុងការធានាថវិកា ខាងការងារបច្ចេកទេស ក្រសួងការពារជាតិត្រូវប្រកាសថវិកា ចំណាយដោយ មានការបែងចែកជាពីរផ្នែក គឺមួយផ្នែកផ្តល់អោយនាយកដ្ឋានសំភារៈបច្ចេកទេសសំរាប់បំរើការ ងារជួសជុលធ្ងន់ គ្រឿងបន្លាស់ធំៗ និងការងារជួសជុលស្រាលកណ្តាលឯកភាពចំណុះក្រសួង ។ មួយ ផ្នែកទៀតអោយអគ្គសេនាធិការ ដើម្បីធ្វើផែនការបែងចែកទៅអោយកណ្តាលឯកភាព ដែលស្ថិតនៅក្រោមចំណុះខ្លួន ។ ក្នុងការបែងចែកមុខចំណាយនេះ អគ្គសេនាធិការត្រូវកំណត់ មុខចំណាយអោយបានច្បាស់ទៅតាមភូមិភាគ និង កងឯកភាពចំណុះខ្លួនសំរាប់ជាសោហ៊ុយជួសជុល ស្រាល និង ថែរក្សាបច្ចេកទេសប្រចាំ ។ ក្នុងករណីដែលអគ្គសេនាធិការត្រូវការថវិកាជួសជុល និង ទិញម៉ាស៊ីនសំរាប់បំរើក្នុងយុទ្ធនាការពិសេសត្រូវធ្វើគំរោងសុំបន្ថែមពីក្រសួងការពារជាតិ ។ ចំពោះ ការបង្គ្រប់ ដូចជាការកសាងរោងចក្រផលិត (បើកដំណើរការកិច្ចសន្យាជាសំណង់រួចហើយ

គ្រឿងបំពាក់អាវុធយុទ្ធភណ្ឌគ្រឿងបន្លាស់ចាំបាច់ ព្រមឯកទេស គឺក្រសួងការពារជាតិជាអ្នកទទួលបន្ទុកដោយសុំសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

ប្រការ ៨ : រាល់ស្ថាប័នជំនាញពាក់ព័ន្ធកិច្ចរបស់ក្រសួងការពារជាតិមិនអាចជួលក្រសួងការពារជាតិក្នុងការតាមដាន និង ត្រួតពិនិត្យអោយបានត្រឹមត្រូវនូវការផ្គត់ផ្គង់ និងប្រើប្រាស់ផលិតសំភារៈភស្តុភារ សំភារៈបច្ចេកទេស ដោយបានបើកផែត និងប្រើប្រាស់ទៅតាមគោលដៅកងឯកភាព ។

ប្រការ ៩ : ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវចាត់តាំងគ្រប់គ្រងរាល់ផលិតា សំភារៈភស្តុភារ និង សំភារៈបច្ចេកទេស ដូចមានចែងខាងលើ អោយបានល្អត់ចត់ល្អតាមលំការពារពីការខ្ជះខ្ជាយ និងបំរើសំណួមពោប្រយុទ្ធ និងកសាងកងយោធពលខេមរភូមិន្ទ អោយមានប្រសិទ្ធភាពខ្ពស់ ។ បុគ្គលណាប្រព្រឹត្តល្មើស ដោយធ្វើអោយបាត់បង់ ឬ លួចកិបកេងលើផលិតសំភារៈបរិក្ខារទាំងនេះត្រូវទទួលវិន័យ និង ទទួលទោសតាមបទបញ្ញត្តិជាធរមាន ។

ប្រការ ១០ : បទបញ្ញត្តិណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១១ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩

សេចក្តីសំរេចលេខ ២៨ សសរ

ស្តីពីការបង្កើតគណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី សំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ និង បច្ចេកទេស

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១៖ បង្កើតគណៈកម្មការមួយមានឈ្មោះថា : " គណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី សំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ និងបច្ចេកទេសដែលមានសមាសភាពដូចតទៅ ÷

១-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	ប្រធាន
២-តំណាងក្រសួងផែនការ " ថ្នាក់នាយកដ្ឋាន "	សមាជិក
៣-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ថ្នាក់នាយកដ្ឋាន "	សមាជិក
៤-តំណាងក្រសួងពាណិជ្ជកម្ម " ថ្នាក់នាយកដ្ឋាន "	សមាជិក
៥-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន " ថ្នាក់នាយកដ្ឋាន "	សមាជិក
៦-តំណាងក្រសួងអប់រំយុវជន និង កីឡា " ថ្នាក់នាយកដ្ឋាន "	សមាជិក
៧-តំណាងក្រសួងការពារជាតិ " ថ្នាក់នាយកដ្ឋាន "	សមាជិក
៨-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ " ថ្នាក់នាយកដ្ឋាន "	សមាជិក
៩-តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ " ថ្នាក់នាយកដ្ឋាន "	សមាជិក
១០-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល " ថ្នាក់នាយកដ្ឋាន "	សមាជិក
១១-តំណាងក្រសួងសុខាភិបាល " ថ្នាក់នាយកដ្ឋាន "	សមាជិក
១២-តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១៣-មន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	លេខាធិការ

ប្រការ ២ : គណៈកម្មការអន្តររដ្ឋាភិបាល កម្ពុជា_រុស្ស៊ី មានភារកិច្ចដូចតទៅ ÷

- ជំនួយការអោយរាជរដ្ឋាភិបាល លើការងារសហប្រតិបត្តិការសេដ្ឋកិច្ច_ពាណិជ្ជកម្ម វិទ្យាសាស្ត្រ និង បច្ចេកទេស
- សំរបសំរួលជាមួយបណ្ដាក្រសួង ស្ថាប័នដែលពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការកម្ពុជា_រុស្ស៊ី
- ពិភាក្សារៀបចំគំរោងការងារ ដែលមានលទ្ធភាពធ្វើសហប្រតិបត្តិការទៅតាមវិស័យនិមួយៗ
- ជំរុញការអនុវត្តកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ
- ត្រួតពិនិត្យការអនុវត្តន៍ កិច្ចសហប្រតិបត្តិការដែលភាគីទាំងពីរបានព្រមព្រៀងគ្នា
- ពិនិត្យ សិក្សាផ្ដល់មតិ និង លើកវិធានការលើវាល់ឯកសារពាក់ព័ន្ធ ដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល តាមកាលកំណត់ ។

ប្រការ ៣ : គណៈកម្មការអន្តររដ្ឋាភិបាល កម្ពុជា_រុស្ស៊ី មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ ឬ តំណាងក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការងារ សហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដើម្បីចូលរួមបំពេញការងារតាមការជាក់ស្តែង ។

ប្រការ ៤ : សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំ និង ធ្វើការងារតាមសេចក្តីអញ្ជើញ និង ការណែនាំរបស់ប្រធាន ។

ប្រការ ៥ : គណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា_រុស្ស៊ី មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិ ជាផ្លូវការ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួង

សុខាភិបាល ត្រូវសហការអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

***

៣. សារាចរ

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៥

សារាចរស្តីពីសេចក្តីព្រាងច្បាប់លេខ ០៣ សរ គណៈរដ្ឋមន្ត្រីដែលបានអនុម័តហើយ

រាជរដ្ឋាភិបាលបានធ្វើការកត់សំគាល់ឃើញថា កន្លងមកក៏ដូចជានៅពេលថ្មីៗនេះ មានក្រសួងខ្លះជូនកាលតំណាងដោយរដ្ឋមន្ត្រី ជូនកាលតំណាងដោយថ្នាក់ដឹកនាំបន្ទាប់ៗអមដោយទីប្រឹក្សាខ្មែរ ឬ បរទេស សុំធ្វើការកែប្រែ បន្ថែមបន្ថយ ឬ វិសោធនកម្មលើសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ដែលគណៈរដ្ឋមន្ត្រីបានអនុម័ត រួចហើយចំពោះមុខគណៈកម្មាធិការនៃរដ្ឋសភា ដែលជាអំពើផ្ទុយនឹងគោលការណ៍ច្បាស់ មិនគោរពបន្ទាត់នយោបាយរបស់រាជរដ្ឋាភិបាល និង មិនគោរពសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី ។

សេចក្តីព្រាងច្បាប់ ដែលធ្វើដោយក្រសួង ស្ថាប័ននិមួយៗរួចហើយដែលបានអនុម័តដោយគណៈរដ្ឋមន្ត្រីរួចហើយគឺ ជាសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល មិនអាចធ្វើការកែប្រែ ឬធ្វើវិសោធនកម្មលើមាត្រាខ្លះ ឬ បន្ថែមបន្ថយលើមាត្រាខ្លះបានឡើយដោយគ្មានការឯកភាព ពីប្រមុខរាជរដ្ឋាភិបាល ឬពីគណៈរដ្ឋមន្ត្រីមុននឹងសភាពេញអង្គពិភាក្សា និង អនុម័ត ។

តំណាងនៃរាជរដ្ឋាភិបាល ដែលត្រូវបានអនុញ្ញាតអោយអញ្ជើញទៅការពារសេចក្តីព្រាងច្បាប់នៅចំពោះមុខ គណៈកម្មាធិការរដ្ឋសភា អាចធ្វើការកែប្រែ ឬ សំរបសំរួលពាក្យពេចន៍

ប្លាប្រយោគ តែមិនប៉ះពាល់ដល់ខ្លឹមសារនៃសេចក្តីព្រាងច្បាប់ឡើយ ។ ក្នុងករណីចាំបាច់ ដែលតម្រូវអោយធ្វើការកែប្រែបន្ថែមបន្ថយ ឬ វិសោធនកម្ម តំណាងនៃរាជរដ្ឋាភិបាលដែលទទួលភារកិច្ចការពារច្បាប់ ត្រូវសុំការអនុញ្ញាត និង ការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ឬ ពីគណៈរដ្ឋមន្ត្រី ។

សេចក្តីដូចបានជំរាបជូនខាងលើនេះ រាជរដ្ឋាភិបាល សូមទាញអារម្មណ៍ ឯកឧត្តមជាប្រធានស្ថាប័ននានា ចំណុះរាជរដ្ឋាភិបាល

-អោយគោរពអោយបានហ្មត់ចត់ និងដោយស្មារតីស្មោះត្រង់នូវរាល់ការអនុម័តរបស់រាជរដ្ឋាភិបាល ចំពោះសេចក្តី ព្រាងច្បាប់នានា ដែលបញ្ជូនទៅអោយរដ្ឋសភា ។

-អោយខិតខំការពារសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល នៅចំពោះមុខគណៈកម្មាធិការនៃរដ្ឋសភាក៏ដូចជានៅ ចំពោះមុខសម័យប្រជុំពេញអង្គនៃរដ្ឋសភាស្តីពីការពិនិត្យ និង អនុម័តសេចក្តីព្រាងច្បាប់ទាំងនោះ ។

ក្រោយពេលទទួលបានសារាចរនេះ គ្រប់ក្រសួងស្ថាប័ន ទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល លើការអនុវត្តន៍អោយមានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

III- ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤៥ សហវ ៥ ប្រក

ស្តីអំពីការផ្ទេរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។

-បានឃើញព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និង ព្រះរាជក្រមលេខ ១០ នស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

-បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៥ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែក ឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥ ។

-បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានក្នុងជំពូកតាម ប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌជូនបណ្តាក្រសួងតាមឥណទាន ចែងក្នុង ច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥ ។

-បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានថវិកាឆ្នាំ ១៩៩៥ ។

-តាមសំណើរបស់ក្រសួងមហាផ្ទៃ លេខ ៤១១-៤១២ សហណ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងលេខ ៤០៧ សហណ ចុះថ្ងៃទី ០៥ ខែ ធ្នូ ១៩៩៤ ។

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិ នៅក្នុងវង្វង់ថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការផ្ទេរឥណទានដូចបាន បញ្ជាក់ខាងក្រោមនេះ :

-ផ្នែកទី ២ : រដ្ឋបាលទូទៅ

ប្រភេទទី ១ : មធ្យោបាយសេវា

ជំពូក ១២ : ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណរដ្ឋបាល

ប្រការ ០១ : ប្រាក់ឧបត្ថម្ភខេត្ត-ក្រុង

ទឹកប្រាក់ត្រូវដក : ៣២.០០០.០០០ រៀលគត់

-ផ្ទេរទៅ :

ផ្នែកទី ៩ : ខេត្តនានា (ស្វាយរៀង)

ប្រភេទទី ១ : មធ្យោបាយសេវា

ជំពូកទី ១២ : ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណរដ្ឋបាល

ប្រការ ០១ : ឧបត្ថម្ភខេត្ត-ក្រុង

ទឹកប្រាក់ត្រូវបន្ថែម : ៣២.០០០.០០០ រៀលគត់

ប្រការ ២ : ឥណទានដែលបានផ្ទេរក្នុងប្រការខាងលើនេះ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវផ្តល់តាមបញ្ជាចំណាយអោយសាលាខេត្តស្វាយរៀង សំរាប់ទូទាត់ការចំណាយទទួលគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ។

ប្រការ ៣ : ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តមអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

២. ធីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ២០៦ ជក.ប្រក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក អៀ ស៊ុម ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៤៣៩៦៣ ក.ព ចុះថ្ងៃទី ២១-០១-៨៥ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥១ ផ្លូវលេខ ៤៤០ សង្កាត់ទួលទំពូងទី ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការ ផលិតកម្ម ពោះវៀនកង់-ម៉ូតូ ឈ្មោះ " តាំង តឹមម៉េង (NTD) " នៅក្នុងទីតាំង ភូមិឫស្សី សង្កាត់ ស្ទឹងមានជ័យ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក អៀ ស៊ុម ត្រូវបានអនុញ្ញាតអោយផលិតពោះវៀនកង់-ម៉ូតូ សញ្ញា " BM UNION TYRE " " WINLUBBER " និង " DEESTONE " ស្របតាមតំរូវផ្លាកសញ្ញា និង សញ្ញាសំគាល់ដែលបានតំកល់នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

៣. ធីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១២ គណប្រ

ស្តីពីការតែងតាំង ជាបណ្តោះអាសន្នចំពោះ

មន្ត្រីរាជការនៃមន្ទីរទេសចរណ៍ខេត្ត បន្ទាយមានជ័យ

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

-យោងប្រកាសលេខ ៧៣១ កទច ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្ដីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរទេសចរណ៍ ខេត្តបន្ទាយមានជ័យ ។

-យោងលិខិតលេខ ៣៨២ ខបជ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៤ របស់អភិបាលខេត្ត បន្ទាយមានជ័យ ស្ដីពីប្រកាសតែងតាំងមន្ត្រីរាជការ មន្ទីរទេសចរណ៍ ខេត្ត បន្ទាយមានជ័យ ។

-យោងប្រកាសលេខ ៩៤៣ កទច ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្ដីពីការតែងតាំងជាបណ្ដោះអាសន្នចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ ។

-យោងលិខិតលេខ ៧២៥ ខបជ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ របស់ឯកឧត្ដមអភិបាលខេត្ត ស្ដីពីការសុំប្ដូរមន្ត្រីរាជការ ចំនួន ០១រូបរបស់មន្ទីរទេសចរណ៍ខេត្ត បន្ទាយមានជ័យ ។

-យោងតាមសំណូមពរការកិច្ច ចាំបាច់នៃការងារអភិវឌ្ឍន៍ នៃវិស័យទេសចរណ៍ ។

សំរេច

ប្រការ ១ : តែងតាំងលោក **ភោគ ឃុន** ជាអនុប្រធានការិយាល័យឧស្សាហកម្មទេសចរណ៍ផែនការ និងផ្សព្វផ្សាយ ជំនួសលោក ប្លែក វ៉ារី ដែលជាប់ភារកិច្ចនៅសាលាខេត្ត បន្ទាយមានជ័យ ។

ប្រការ ២ : នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្ត បន្ទាយមានជ័យ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា ។

ជ-រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ថោង ខុន

***

៤- ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២១២ ប្រក.សក.ឋ
ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធន៍បើក អោយប្រើប្រាស់ផ្លូវជាតិលេខ ៦ អា ក្រោមព្រះរាជអធិបតីភាព ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣

-យោងតាមការងារចាំបាច់របស់ក្រសួង ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយរៀបចំពិធីសម្ពោធន៍បើកអោយប្រើប្រាស់ផ្លូវជាតិលេខ ៦ អា ដែលមានសមាសភាពដូចខាងក្រោមនេះ ÷

១-ឯកឧត្តម **ជិន គឹមស្រេង**	អនុរដ្ឋលេខាធិការ	ប្រធាន
២-លោក **សៀង ហាក់**	អគ្គនាយក	អនុប្រធាន
៣-ឯកឧត្តម **ថាច់ រ៉េង**	នាយខុទ្ទកាល័យ	សមាជិក
៤-លោក **តាន់ ហៃសៀន**	ប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធ	សមាជិក
៥-លោក **កុយ គីមផន**	អគ្គាធិការដ្ឋាន	សមាជិក
៦-លោក **អ៊ឹក ចាន់**	អនុប្រធាននាយកដ្ឋានការងារថ្មី	សមាជិក
៧-លោក **ក្ងួច ចាន់កុសល**	អនុប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធ	សមាជិក
៨-លោក **ហ៊ាន់ ផន**	មន្ត្រីទទួលបន្ទុកការងារសហប្រតិបត្តិការ	សមាជិក
៩-លោក ស្រី **អ៊ុង ឈាងលី**	នាយកវិយាល័យ គណនេយ្យ-ហិរញ្ញវត្ថុ	សមាជិក
១០-លោក **មាស សាមិត**	មន្ត្រីទទួលបន្ទុកការងារពត៌មាន	សមាជិក
១១-លោក **ឈួន ឆាយា**	នាយកវិយាល័យ បុគ្គលិក-ធនធានមនុស្ស	សមាជិក
១២-លោក **មៀច ឈួន**	នាយកវិយាល័យ រដ្ឋបាល	សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចទទួលខុសត្រូវ រៀបចំចាត់ចែងតុបតែងលំអ រៀបចំសុន្ទរកថាជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រៀបចំពិធីការទទួលនិងអញ្ជើញភ្ញៀវ ការពារសុវត្ថិភាព សណ្តាប់ធ្នាប់ទទួលភេសជ្ជៈ និងចាត់តាំងមន្ត្រីរាជការតាមអង្គភាពចូលរួមអោយបាន អធិកអធមក្នុងពិធីសម្ពោធន៏នេះ ដែលប្រព្រឹត្តទៅនៅថ្ងៃ ២៧ ខែ មីនា ឆ្នាំ ១៩៩៥ ខាងមុខនេះ ។

-សមាជិកគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ ៣ : លោក អគ្គនាយក នាយខុទ្ទកាល័យ និងអស់លោក លោកស្រី ដែលមានរាយនាមខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន

ហត្ថលេខា និង ត្រា

អ៊ុង សាត

***

៥. ធីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៦២/៩៥ ពម

ប្រការ ១ : អនុញ្ញាតអោយលោកស្រី **ស៊ីម ជល្លីន** ស្ថិតនៅផ្ទះលេខ ៨០ អឺ០ ផ្លូវលេខ ១៣៨ ក្រុម ៤ សង្កាត់ផ្សារដេប៉ូ២ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ "ព្រះអាទិត្យ" ស្ថិតនៅលំនៅខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់ សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ២ សាមីខ្លួន នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ- សោតទស្សន៍ នៃអគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពអនុវត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

***

ប្រកាសលេខ ០៦៤/៩៥ ពម.ប្រក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៥
ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

ប្រការ ១ : លុបឈ្មោះអ្នកស្រី **កែច សុធារី** បុគ្គលិកមន្ទីរពត៌មានខេត្ត កំពង់ឆ្នាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ដោយសាមីខ្លួនស្ម័គ្រចិត្តសុំឈប់ ។

ប្រការ ២ : អ្នកស្រី **កែច សុធារី** ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលប្រាក់ឧបត្ថម្ភប្តូរផ្តាច់ ស្មើនឹងប្រាក់បៀវត្សអ្នកស្រី **កែច សុធារី** ៣២.១១០ គុណ 10 ស្មើ ៣២១.100រៀល

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរពត៌មានខេត្ត កំពង់ឆ្នាំង និង សាមីខ្លួនមានភារៈអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

***

៦. ផ្នែកការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍

ប្រកាស

ប្រកាសលេខ ៥៧៨ អ.ជ.ប ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥
ស្តីពីការទទួលក្របខ័ណ្ឌបុគ្គលិកមន្ត្រីរាជការ

ប្រការ ១ : ទទួលក្របខ័ណ្ឌបុគ្គលិករដ្ឋបាល របស់ភាគីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ចំនួន ៥៥៤ នាក់ អោយមកបំរើការងារក្នុងក្របខ័ណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ ។

ប្រការ ២ : ចាត់តាំងបុគ្គលិក-មន្ត្រីរាជការ នៃក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានចែងក្នុងប្រការ ១ អោយទៅបំរើតាមបណ្តាស្ថាប័ននានាចំណុះក្រសួង និងតាមមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដោយជូនភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធ នៃសេចក្តីប្រកាសនេះ ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានអធិការកិច្ច គ្រប់នាយកដ្ឋាន បណ្តាមន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ ព្រមទាំងសាមីជនត្រូវអនុវត្តតាមប្រកាសនេះ អោយបានប្រសិទ្ធភាព ។

ប្រការ ៤ : សេចក្តីប្រកាសនេះ ចាប់ចូលជាធរមានបញ្ញត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

យឹម ឆៃលី

***

៧. ផ្នែកការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១២ ប្រក.កសក.ចក
ស្តីពីការតែងតាំង មន្ត្រីរាជការ

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់ តាំងរបស់ ក្រសួងកសិកម្ម

-បានឃើញដីកាលេខ ៣២៩ ខច ចុះថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល និង តែងតាំងភារកិច្ចរបស់ខេត្ត កំពង់ចាម

-យោងលិខិតលេខ ២៦១៣ កសក.ចត ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការរក្សាទុកមន្ត្រីរាជការ និយោជិក តាមការិយាល័យនីមួយៗនៃមន្ទីរកសិកម្មខេត្ត ក្រុង

សំរេច

មាត្រា ១ : ចាត់តាំងលោក **ម៉ាន់ ឆាន** អតីតអនុប្រធានមន្ទីរ និងជាប្រធានការិយាល័យផលផល នៃមន្ទីរកសិកម្មខេត្ត កំពង់ចាម អោយទៅជាអនុប្រធានមន្ទីរកសិកម្មខេត្តទទួលបន្ទុកការងារ ការិយាល័យផលផល និង ការិយាល័យ គ្រឿងយន្តកសិកម្ម ។

មាត្រា ២ : ដីកាលេខ ៣២៩ កច ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៤ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ ស្ថិតិ ប្រធាននាយកដ្ឋានជលផល ប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម និង សាមីជនត្រូវ អនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សេងហួរ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១៥ ប្រក.កសក.ចក
ស្តីពីការបង្កើតមន្ទីរកសិកម្មក្រុងកែប

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត ១០៩៤/៧៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម

-បានឃើញសារាចរណែនាំលេខ ៣៧ ចត.កសក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៨៦ របស់ក្រសួងកសិកម្ម ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីន មន្ទីរកសិកម្មខេត្ត-ក្រុង

-បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្តូររចនាសម្ព័ន្ធរដ្ឋបាលក្រុងកែប ពីថ្នាក់ស្រុកមកជាថ្នាក់ក្រុង

-បានឃើញ ការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សំរេច

មាត្រា ១ : បង្កើតមន្ទីរកសិកម្មក្រុងកែបចំណុះផ្ទាល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានទីតាំង នៅក្រុងកែប និងមានតួនាទីភារកិច្ចគ្រប់គ្រងដឹកនាំគ្រប់សកម្មភាពការងារក្នុងវិស័យកសិកម្ម ។

មាត្រា ២ : មន្ទីរកសិកម្មក្រុងកែបរួមមាន ៤ ការិយាល័យ :

១-ការិយាល័យ រដ្ឋបាលបុគ្គលិក

២-ការិយាល័យ រុក្ខាប្រមាញ់ និងនេសាទ

៣-ការិយាល័យ ក្សេត្រសាស្ត្រ ធារាសាស្ត្រ

៤-ការិយាល័យ ផលិតកម្ម និងពេសុព្យាបាល

មាត្រា ៣ : មន្ទីរកសិកម្មក្រុងកែបត្រូវបានដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជាជំនួយការ ។

មាត្រា ៤ : ក្របខ័ណ្ឌការរៀបចំ និង ការប្រព្រឹត្តទៅនៃមន្ទីរកសិកម្មក្រុងកែបត្រូវកំណត់ដោយប្រកាសរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ ប្រធាននាយកដ្ឋាន គណនេយ្យ-ហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សេងហួរ

***

៨. ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៩១ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ « សាលាមត្តេយ្យមិត្តភាព ភ្នំពេញហាណូយ »

ទៅជា » សាលាបឋមសិក្សាមិត្តភាពភ្នំពេញហាណូយ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតលេខ ២៦៣០ ៧.ស ចុះថ្ងៃទី ២៥ តុលា ១៩៩៤ របស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ស្តីពីករណីសុំប្តូរឈ្មោះសាលាមត្តេយ្យមិត្តភាពហាណូយ
- តាមសំណើរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : ប្តូរឈ្មោះ " សាលាមត្តេយ្យមិត្តភាព ភ្នំពេញ ហាណូយ " ដែលមានទីតាំងនៅស្រុក ដង្កោ រាជធានីភ្នំពេញ ទៅជា " សាលាបឋមសិក្សា មិត្តភាព ភ្នំពេញ ហាណូយ " ។

ប្រការ ២ : សាលាបឋមសិក្សានេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងមន្ត្រីរាជការផ្សេងៗទៀតមួយចំនួនតាមអង្គការលេខនៃសាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករងនៃសាលាបឋមសិក្សា មានសិទ្ធិទទួលប្រាក់បំណាច់ការកិច្ចរបស់នាយក នាយករងនៃសាលាបឋមសិក្សា ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយដ្ឋានផែនការ ហិរញ្ញកិច្ច និងប្រធាននាយកដ្ឋានចាត់តាំង នៃក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចរៀងៗខ្លួន អនុវត្តសេចក្តីសំរេចនេះ ។

រដ្ឋមន្រ្តីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

តា សាហាន

* * *

៩- ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៨/៩៥ ក.ធ.ស

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ

របស់មន្រ្តីរាជការ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្រ្តីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងបច្ចេកទេសសិក្សា ប្រធាននាយដ្ឋានផែនការ ហិរញ្ញកិច្ច និងប្រធាននាយកដ្ឋានចាត់តាំង នៃក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចរៀងៗខ្លួន អនុវត្តសេចក្តីសំរេចនេះ ។

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាហាន

***

៩- ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៨/៩៥ ក.ធ.ស

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ

របស់មន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា

- បានឃើញលិខិតលេខ ១១១_៩៤ មសខ.ក្រច ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៤ របស់មន្ទីរធម្មការ និង សាសនាខេត្តក្រចេះ

សំរេច

ប្រការ ១ : លោក **ឃី សី** បច្ចុប្បន្នជាអនុប្រធានមន្ទីរធម្មការនិងសាសនាខេត្តក្រចេះ ត្រូវផ្ទេរអោយទៅបំរើការងារនៅមន្ទីរ អភិវឌ្ឍន៍ជនបទខេត្ត ក្រចេះ ។

ប្រការ ២ : ផ្ទេរបៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **ឃី សី** ជូនក្រសួងអភិវឌ្ឍន៍ជនបទ ។

ប្រការ ៣ : មន្ទីរធម្មការនិងសាសនាខេត្តក្រចេះ ក្រសួងអភិវឌ្ឍន៍ជនបទ និង លោក **ឃី សី** ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារ័ត្ន

***

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៦៣០ រៀល